ASIAN & PACIFIC ISLANDER AMERICAN HEALTH FORUM

ខែតុលា ឆ្នាំ ២០២៣

# សំណួរដែលគេសួរញឹកញាប់អំពីកម្មវិធី Bridge Access របស់ CDC

លទ្ធភាពទទួលបានវ៉ាក់សាំងកូវីដ-១៩ សម្រាប់អ្នកដែលមិនមានការធានារ៉ាប់រង និងអ្នកមានការធានារ៉ាប់រងមិនគ្រប់គ្រាន់

## តើកម្មវិធី Bridge Access ជាអ្វី?

កម្មវិធីនេះផ្តល់វ៉ាក់សាំងកូវីដ-១៩ ដោយឥតគិតថ្លៃដល់មនុស្សពេញវ័យ (មនុស្សអាយុ ១៨ ឆ្នាំឡើងទៅ) ដែលមិនមានការធានារ៉ាប់រង ឬ មានការធានារ៉ាប់រងដែលមិនរ៉ាប់រងលើថ្លៃចំណាយលើវ៉ាក់សាំងកូវីដ-១៩ ទាំងអស់។




## ចុះចំណែកកុមារដែលគ្មានការធានារ៉ាប់រង ឬកុមារដែលមានការធានារ៉ាប់រងមិនគ្រប់គ្រាន់?

មនុស្សដែលមានអាយុក្រោម ១៩ ឆ្នាំដែលមិនមានការធានារ៉ាប់រង ឬ ជាសមាជិកនៃកុលសម្ព័ន្ធ ដែលទទួលស្គាល់ដោយសហព័ន្ធនឹងស្ថិតនៅក្រោមការធានារ៉ាប់រងដោយកម្មវិធីវ៉ាក់សាំងសម្រាប់កុមារ (VFC)។



## តើអ្នកជំងឺចុះឈ្មោះក្នុងកម្មវិធីនេះដោយរបៀបណា?

មិនមាន *ដំណើរការចុះឈ្មោះសម្រាប់មនុស្សពេញវ័យ* ដែលមានសិទ្ធទទួលបានវ៉ាក់សាំងកូវីដ-១៩ ដោយមិនគិតថ្លៃតាមរយៈកម្មវិធីនេះទេ។ អ្នកផ្តល់សេវានឹងសួរអ្នកជំងឺថា តើពួកគេមានការធានារ៉ាប់រងសុខភាពឬអត់ ដើម្បីកំណត់ពីសិទ្ធទទួលបាន។



## តើខ្ញុំអាចទទួលបានវ៉ាក់សាំងកូវីដ-១៩ ដោយមិនគិតថ្លៃតាមរយៈកម្មវិធីនេះនៅឯណា?

អ្នកអាចស្វែងរកវ៉ាក់សាំងកូវីដ-១៩ដោយមិនគិតថ្លៃតាមរយៈកម្មវិធីនេះនៅតាមអ្នកផ្តល់សេវាសុខភាពក្នុងស្រុក មជ្ឈមណ្ឌលសុខភាព និងឱសថស្ថានដែលចូលរួមសហការ។ សូមចូលទៅកាន់ www.vaccines.gov ដើម្បីស្វែងរកទីតាំង!




## តើវ៉ាក់សាំងកូវីដ-១៩ ឥតគិតថ្លៃនឹងមានផ្តល់ជូនរយៈពេលប៉ុន្មាន តាមរយៈកម្មវិធីនេះ?

កម្មវិធី Bridge Access នឹងផ្តល់វ៉ាក់សាំងកូវីដ-១៩ ដោយឥតគិតថ្លៃរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤។

ដើម្បីអានបន្ថែម សូមចូលទៅកាន់ www.CDC.gov/vaccines/programs/bridge។




This publication was made possible by cooperative agreement CDC-RFA-IP21-2106 from the Centers for Disease Control and Prevention (CDC) of the U.S. Department of Health and Human Services (HHS). Its contents are solely the responsibility of the authors and do not necessarily represent the official views of CDC/HHS.